 A003 2/21/2013 8:03 AM (16) 26-01-2012 5 mam 32/4

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ៖ ១៦

ចុះថ្ងៃទី២៦-០១-២០១២

**សាលដីកា**

លេខ ៖ ១០៣ ក្រ II

ចុះថ្ងៃទី១២-១១-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ស្តីពី ការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យ-ច្បាប់ លេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី **១៩-១០-២០១២** ដោយមានសមាសភាពដូចខាងក្រោម ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

- ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ **១៦** ចុះថ្ងៃទី **២៦-០១-២០១២** ដែលមាន ៖

**ជនជាប់ចោទឈ្មោះ** [redacted] **ចណ្ណាណាត** ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើតសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅមុន [redacted]) សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុន គ្មាន។

**ជាប់ចោទពីបទ៖** ការចាប់ឃុំឃាំងនិងបង្ខាំងដោយខុសច្បាប់ដោយមានស្ថានទម្ងន់ (ក្នុងគោលដៅជំរិតទ្រព្យសម្បត្តិ) និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត្តិ ប្រព្រឹត្តនៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ក្រុងព្រះសីហនុ កាលពីថ្ងៃទី២៧ និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៥៣ , ២៥៤ និងមាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។



Scanned by CamScanner

**-ជនរងគ្រោះឈ្មោះ [redacted] សោភា** ភេទស្រី អាយុ ១៩ឆ្នាំ ទីកន្លែងកំណើតសង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃនៅផ្ទះលេ[redacted]ខណ្ឌ៧មករា រាជធានីភ្នំពេញ មុខរបរសិស្ស នៅលីវ ម្ដាយឈ្មោះ [redacted](រ) ឪពុកឈ្មោះ [redacted] (រ) ។

**ឯរឿងហេតុមានដូចតទៅះ**

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១៣:៣០នាទី ដោយមានគម្រោងរៀបចំជាមុន ឈ្មោះ [redacted] វណ្ណណាត ហៅ ដេត បានធ្វើសកម្មភាពបើកទ្វាររថយន្តចូលក្នុងដោយអាវុធខ្លីពុំស្គាល់ម៉ាកលើឈ្មោះ [redacted] សោភា ហៅ ប៊ី ភេទស្រី អាយុ ១៩ឆ្នាំ ខណៈពេលជន រងគ្រោះកំពុងអង្គុយក្នុងរថយន្តម៉ាកកាមរីសេរី២០០២ ពណ៌ទឹកប្រាក់ ផ្លាកលេខភ្នំពេញ ២M-៨៣១៥ នៅមុំសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងសង្កាត់វត្តភ្នំ និងបង្ខំឲ្យជនរងគ្រោះបើក រថយន្តចេញពីចំណុចកើតហេតុ និងបានប្ដូរបើកដោយខ្លួនឯងឆ្ពោះទៅខេត្តព្រះសីហនុ ដោបាន បង្ខាំងទុកជនរងគ្រោះនៅបន្ទប់លេខ ១១២ សណ្ឋាគារខ្សាច់មាស ដោយចងដៃជើង និងយកស្កត់បិទមាត់ជនរងគ្រោះ ហើយបានទូរសព្ទទាក់ទងម្ដាយជនរងគ្រោះទារប្រាក់ចំនួន **៣០០.០០០$ (សាមសិបម៉ឺនដុល្លាអាមេរិក)** ។ នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១១ ជនល្មើសបានទូរសព្ទទៅម្ដាយជនរងគ្រោះម្ដងទៀត និងបានទារប្រាក់ត្រឹម **១៥០.០០០$ (ដប់ប្រាំម៉ឺនដុល្លាអាមេរិក)** ដោយកំណត់ត្រឹមម៉ោង ១៤ នៅផ្សារ CITY MALL ភ្នំពេញ ហើយចងដៃជើង និងបិតស្កុតបិទមាត់ជនរងគ្រោះដោយជិះរថយន្តឈ្នួលមកភ្នំពេញ ដើម្បីទទួលប្រាក់ពីមកជួបម្ដាយជនរងគ្រោះក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន នៅពេលកំពុងធ្វើសកម្មភាព ចំណែកជនរងគ្រោះបានរើចំណងរួចក៏ទៅប្ដឹងសមត្ថកិច្ច ។ ក្រោយពីឃាត់ខ្លួនឈ្មោះ [redacted] វណ្ណណាត សមត្ថកិច្ចបានរកឃើញអាវុធមួយដើមដែលធ្វើសកម្មភាព ។

**-បានឃើញ សេចក្ដីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៖ ១១៤ ក្រ ៦ ៩ ចុះថ្ងៃទី ០៦-១០-២០១១ សំរេចថា ៖**

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត ហៅ ដេត ភេទប្រុស អាយុ ២៩ឆ្នាំ (មានសារគាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ១.០០០.០០០រៀល (មួយលានរៀល) ពីបទៈ **ការចាប់ និងបង្ខាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ"** និងបទកាន់កាប់អាវុធដោយគ្មានអនុញ្ញាត ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី**២៧, ២៨** ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា **២៥៣ , ២៥៤** និងមាត្រា **៤៩០** នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២-វត្ថុតាងចាប់យករួមមានៈ

ក-កាំភ្លើងខ្លីមួយដើមមិនស្គាល់ម៉ាក, បង់មួយមានចំនួនពីរគ្រាប់ , ស្កត់សំរាប់បិតមាតចំនួនពីរបន្ទះ ,ខ្សែចំណងរុត (ខ្សែសៀល) មិនប្រើចំនួន ៣១ខ្សែ និងប្រើរួចចំនួនបួនខ្សែ រឹបអូស និងបំផ្លាញចោល ។

ខ-ទូរសព្ទមួយគ្រឿងម៉ាក NOKIA C6 មានស៊ីម , ស្បែកជើងមួយគូរ , កាបូបក្រណាត់ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ពេលសាលក្រមនេះចូលជាស្ថាពរ ។



Scanned by CamScanner

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត សងជម្ងឺចិត្តចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) ឲ្យទៅជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សោភា ទាមទារលើសពីនេះបដិសេធចោល ។

៤-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១១ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**ឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៦៩៤ ចុះថ្ងៃទី ១១-១០-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៤ ក្រ៦ "ជ" ចុះថ្ងៃទី០៦-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល។

-**ឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

-**ឃើញ** សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **វណ្ណណាត** (វត្តមាន)

-មេធាវីលោក [redacted] **គ្រួយ** ការពារឲ្យជនជាប់ចោទ (វត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted] **សោភា** (អវត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] **វណ្ណណាត** បានឆ្លើយថា: ក្នុងរឿងនេះខ្លួនមិនបានចាប់កូនស្រី គេទេ គឺព្រមទៅជាមួយគ្នា ដំបូងជិះឡានដើរលេងនៅភ្នំពេញ ហើយចង់ទៅកំពង់សោម ទើបនាំគ្នាទៅ ។ ចំពោះការទារលុយគឺធ្វើដើម្បីការពារកិត្តិយសរបស់ [redacted] សោភា ហៅ អាប៊ី ហើយខ្លួនមិនបានចងដៃអាប៊ី ទេ ក្នុងរឿងនេះខ្លួនមិនបានប្រព្រឹត្តទេ ។ សំណូមពរ សុំលើកលែងទោស ។

**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ** :

សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៤ ក្រ៦ ជ ចុះថ្ងៃទី០៦-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-មេធាវីលោក [redacted] **គ្រួយ** ការពារឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា: ក្នុងរឿងនេះកូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់ទេ ការធ្វើនេះគឺដើម្បីការពារកិត្តិយសរបស់ [redacted] សោភា តែប៉ុណ្ណោះ ហើយនៅក្នុងពាក្យបណ្ដឹងរបស់ [redacted] សោភា ក៏បានបញ្ជាក់រួចហើយដែរ សំណូមពរសុំក្រុមប្រឹក្សាពិចារណាតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសុំក្រុមប្រឹក្សាសម្រេចឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទ ។

-ក្រោយពីបានស្ដាប់របាយការណ៍រឿង

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្ដុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សាលាឧទ្ធរណ៍**



Scanned by CamScanner

<u>**យល់ឃើញថា**</u>

១-បណ្តឹងឧទ្ធរណ៍លេខ ៦៩៤ ចុះថ្ងៃទី១១-១០-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណាត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ៦ ជ ចុះថ្ងៃទី ២៦-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបានតាមបញ្ញត្តិច្បាប់ ។

២-នាពេលសួរដេញដោលជនជាប់ចោទបានសារភាពថាបានប្រព្រឹត្តដូចការចោទប្រកាន់របស់អយ្យការពិតមែន តែខ្លួនឆ្លើយសារភាពពេលនេះ ដើម្បីកិត្តិយសខាងកូនស្រីនិង ឪពុកម្តាយកូនស្រីតែប៉ុណ្ណោះ សាលាឧទ្ធរណ៍ពិចារណាពីបទចាប់ និងបង្ខាំងមនុស្សខុសច្បាប់ដោយមានស្ថានទម្ងន់ ក្នុងគោលដៅជំរិតទារយកប្រាក់តែប៉ុណ្ណោះ ។

៣-ការដែលមេធាវីការពារឲ្យជនជាប់ចោទបានធ្វើសន្និដ្ឋានការពារ សុទ្ធតែជារឿងអង្គសេចក្តីដែលសាលាដំបូងបានពិចារណារួចហើយ ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណាត ហៅ ដេត ពីបទ ចាប់និង **បង្ខាំងមនុស្សដោយខុសច្បាប់មានស្ថានទម្ងន់ទោស** ក្នុងគោលដៅជំរិតទារប្រាក់ និងបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត្ត** ដូចអយ្យការចោទប្រកាន់ពិតមែន ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ៦ ជ ចុះថ្ងៃទី០៦-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះ ទុកជាបានការ ។

<u>**ហេតុដូច្នេះ**</u>

<u>**វិនិច្ឆ័យសេចក្តី**</u>

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៨ ក្រ៦ ជ ចុះថ្ងៃទី០៦-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៩-១០-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២-១១-២០១២ ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

... ខែ... ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner